RP ND 62/21.01.15 105/II

សាលាដំបូងខេត្តកំពង់ចាម

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១០៩ ចុះថ្ងៃទី ១៧

ខែ កុម្ភៈ ឆ្នាំ ២០១៤

សាលក្រម

លេខ ៧៣"ក"ចុះថ្ងៃទី ២១

ខែ វិច្ឆិកា ឆ្នាំ ២០១៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ចាម

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជំរះនៃសាលាដំបូងខេត្តកំពង់ចាម
នាថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១៤ វេលាម៉ោងប្រាំបីព្រឹក ។
ដោយមានសមាសភាពដូចខាងក្រោម

### ក្រុមប្រឹក្សាជំនុំជំរះ

-លោក [redacted] ប្រធានសាលាដំបូងខេត្តកំពង់ចាម ជាប្រធានក្រុមប្រឹក្សា
-លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ចាម ជាចៅក្រមប្រឹក្សា
-លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ចាម ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកំពង់ចាម

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម

### មេធាវី

-លោក [redacted] ការពារអោយដើមបណ្តឹងរដ្ឋប្បវេណី
-លោក [redacted] ការពារអោយជនជាប់ចោទ

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១០៩ ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ដែលមានជនជាប់ចោទឈ្មោះ[redacted] **ម៉ារ៉ែន** ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរនគរបាល ទីកន្លែងកំណើតនៅភូមិពេទ្យចិន សង្កាត់លេខ៤ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តកំពង់ចាម ប្រពន្ធឈ្មោះ[redacted] កូនគ្មាន ឪពុកឈ្មោះ[redacted]"រ" ម្តាយឈ្មោះ[redacted]"រ" ប្រវត្តិនៃការផ្តន្ទាទោស គ្មាន (ឃាត់ខ្លួនថ្ងៃទី១៤-០២-២០១៤ ឃុំខ្លួនថ្ងៃទី១៨-០២-២០១៤ ) ។

ជាប់ចោទពីបទៈ **ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]វល័ក្ខណ៍ ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកធនាគារ អេស៊ីលីដា ទីកន្លែងកំណើតនៅភូមិព្រៃទទឹង ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅ[redacted]ខេត្តត្បូងឃ្មុំ ប្តីឈ្មោះ [redacted] មានកូនចំនួន០១នាក់ ,ឪពុកឈ្មោះ[redacted]"ស" ម្តាយឈ្មោះ[redacted]"ស" ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] **គីមស្រ៊ី** ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតនៅភូមិសំរោង ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិទី៦ សង្កាត់[redacted] ខេត្តកំពង់ចាម ប្រពន្ធឈ្មោះ[redacted] មានកូនចំនួន០៣នាក់ ,ឪពុកឈ្មោះ[redacted]"ស" ម្តាយឈ្មោះ [redacted]"រ"

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី០៩-០២-២០១៤ វេលាម៉ោងប្រហែល២៣.៣០នាទីយប់ នៅចំណុចផ្ទះជួល ស្ថិតនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម មានឈ្មោះ[redacted] ម៉ារ៉ែន ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ បានធ្វើសកម្មភាពប្លន់យកទ្រព្យសម្បត្តិ ហើយយកប្រេងសាំងចាក់ដុតទៅលើជនរងគ្រោះឈ្មោះ[redacted]សាថាត ភេទប្រុស អាយុ៥៤ឆ្នាំ បណ្តាលឱ្យស្លាប់បន្ទាប់ពីបញ្ជូនទៅដល់មន្ទីរពេទ្យ ។ បន្ទាប់ពីហេតុការណ៍នេះកើតឡើងមកសមត្ថកិច្ចបានរៀបចំកសាងជាសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ចាត់ការតាមនីតិវិធី ។

បានឃើញកំណត់ហេតុរបាយការណ៍លេខ ២៣/០១៤ ចុះថ្ងៃទី ០៩-០២-២០១៤ របស់ប៉ុស្តិ៍នគរបាលសង្កាត់វាលវង់ (ឯកសារលេខ ១) ។

បានឃើញកំណត់ហេតុស្រាវជ្រាវ និងពិនិត្យទីកន្លែងកើតហេតុ ចុះថ្ងៃទី០៩-០២-២០១៤ របស់អធិការនគរបាលក្រុងកំពង់ចាម (ឯកសារលេខ ២) ។

បានឃើញកំណត់ហេតុពិនិត្យលើសាកសព ចុះថ្ងៃទី ១០-០២-២០១៤ របស់អធិការនគរបាលក្រុងកំពង់-ចាម (ឯកសារលេខ១៣) ។

បានឃើញរបាយការណ៍លេខ ០៨/០១៤ ចុះថ្ងៃទី ១២-០២-២០១៤ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ (ឯកសារលេខ ១៥) ។

បានឃើញរបាយការណ៍សំយោគលេខ ០៧/០១៤ របក ចុះថ្ងៃទី ១៥-០២-២០១៤ របស់អធិការនគរបាលក្រុងកំពង់ចាម (ឯកសារលេខ ៣២) ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៣០ ព.ស ចុះថ្ងៃទី ២៥-០៧-២០១៤ របស់តំណាងអយ្យការអមសាលាដំបូង ខេត្តកំពង់ចាម (ឯកសារលេខ ៨៨) ។

បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១២៨ ព្រ.ទ ចុះថ្ងៃទី ២៥-០៧-២០១៤ របស់ចៅក្រមស៊ើបសួរនៃ សាលាដំបូងខេត្តកំពង់ចាម (ឯកសារលេខ ៨៩) ។

បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ៥២៤ ចត ចុះថ្ងៃទី ០១-០៩-២០១៤ របស់ប្រធានសាលាដំបូងខេត្តកំពង់ចាម ។

## **នាពេលសវនាការ**

ជនជាប់ចោទឈ្មោះ[redacted] **ម៉ារ៉ែន** បានឆ្លើយថា កាលពីថ្ងៃទី០៨-០២-២០១៤ វេលាល្ងាច ខ្លួនបានតេទៅរកឈ្មោះថាត ដើម្បីបបួលទៅហូបអីនៅហាងណាណា ព្រោះឈ្មោះថាត មានស្រីស្នេហ៍នៅទីនោះ ដោយពេលដល់កន្លែងនោះ ខ្លួននិងឈ្មោះថាត បានហៅស្រាបៀរអាន់ឆ័រមកហូប ពួកខ្លួននាំគ្នាហូបរហូតដល់ម៉ោងប្រហែល៨យប់ ទើបចេញពីហាងណាណា ត្រឡប់មកផ្ទះវិញ ។ ពេលនោះខ្លួនជិះម៉ូតូជាមួយគ្នា ហើយជិះមកផ្ទះជួលរបស់ឈ្មោះថាត ដែលនៅចំហៀងសាលាជាតិកសិកម្មខេត្តកំពង់ចាម ក្រោយពីឈ្មោះថាត ចូលផ្ទះរួចខ្លួនក៏ដើរមកសំរាកនៅកន្លែងធ្វើការនៅស្នងការដ្ឋាននគរបាលខេត្តកំពង់ចាមវិញ។ លុះដល់ថ្ងៃអាទិត្យទី០៩ខែកុម្ភៈ ឆ្នាំ២០១៤ វេលាម៉ោង៧.០០ព្រឹក ឈ្មោះថាត បានតេទូរស័ព្ទមកបបួលខ្លួនទៅស្រុកចំការលើ ឃុំបុសខ្នុរ ហើយខ្លួនក៏យល់ព្រមទៅជាមួយ ដោយខ្លួននិយាយតបវិញថា ទៅបានតែកុំទៅយូរពេក ប្រហែល២០នាទីក្រោយមក ឈ្មោះថាតក៏មកយកខ្លួនទៅស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ដោយធ្វើដំណើរទៅដល់ស្រុកចំការលើ ឃុំបុសខ្នុរ ត្រូវចំណាយពេលរយៈពេល០១ម៉ោង ហើយបន្ទាប់មកក៏ឈប់ម៉ូតូនៅមុខសាលាឃុំបុសខ្នុរ ហើយឈ្មោះថាត ក៏នៅនិយាយទូរស័ព្ទនៅបរិវេណសាលាឃុំ ពេលនោះខ្លួនក៏ដើរចូលទៅជិតឈ្មោះថាត តែគេចេះតែដើរគេចចេញរហូត

ហើយនៅតែបន្តនិយាយទូរស័ព្ទអស់ប្រហែលជាងកន្លះម៉ោងទើបឈប់ រួចក៏ជិះម៉ូតូទៅឈប់នៅហាងកាហ្វេផ្សារបុសខ្នុរ ដោយខ្លួនបានហៅកាហ្វេផឹក តែឈ្មោះថាត ពុំបានហៅផឹកទេ គឺនៅតែបន្តនិយាយទូរស័ព្ទទៀត ក្រោយមកឈ្មោះថាត បានដើរចូលមកក្នុងហាងវិញ ហើយប្រាប់ថាបន្តិចទៀតមានស្រីមកហើយ រួចគេក៏ហៅគេឱ្យដាក់គុយទាវយកមកហូប ។ បន្ទាប់មកក៏ឃើញមានមនុស្សស្រីម្នាក់ដើរមក បើតាមដឹងស្រីម្នាក់នោះត្រូវជាម្ដាយស្រីស្នេហ៍របស់ឈ្មោះថាត មួយសន្ទុះក្រោយមកក៏មានស្រីម្នាក់ទៀតដើរចូលមកដែរ ហើយក៏កើតមានការឈ្លោះប្រកែកគ្នា ។ បន្ទាប់មកបែរជាមានមនុស្សប្រុសម្នាក់ទៀតដើរចូលមកក្នុងហាងកាហ្វេដែរ ដោយនិយាយថា បានហើយចាំរកស្រីឱ្យព្រោះពួកគេមានប្រុសផ្សេងហើយ ក្រោយមកឈ្មោះថាត សុំឱ្យមនុស្សប្រុសម្នាក់នោះជិះម៉ូតូជូនទៅមើលមនុស្សស្រីនោះ ដោយនាំគ្នាជិះម៉ូតូហួសហាងកាហ្វេប្រហែល១០០ម៉ែត្រ រួចក៏បន្តធ្វើដំណើរត្រឡប់មកកំពង់ចាមវិញនៅវេលាម៉ោងប្រហែល១១ថ្ងៃត្រង់ ហើយខ្លួននិងឈ្មោះថាតក៏បែកគ្នាទៅផ្ទះរៀង១ខ្លួន។ ចាប់ពីពេលត្រឡប់មកពីស្រុកចំការលើវិញ ខ្លួននៅផ្ទះក្នុងស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ។ លុះដល់ម៉ោងប្រហែល៤ល្ងាចឈ្មោះ[redacted]កុសល( ប៉ូលីស) ឈ្មោះរ៉ាធ្វើការនៅABC KTV( ប៉ូលីស) និងខ្លួន បាននាំគ្នាទៅផឹកនៅហាង ស៊ុបភើខូល ដោយផឹកប្រហែលរយៈពេលជាង២ម៉ោង ខ្លួននិងមិត្តភ័ក្រ្តទាំង០២នាក់ក៏នាំគ្នា បន្តទៅច្រៀងនៅABC KTV ។ ពេលខ្លួនជិះមកដល់មុខហាងខារ៉ាអូខេABC KTV ឈ្មោះថាត ក៏តេទូរស័ព្ទមកខ្លួន ពេលនោះម៉ោងប្រហែល៧យប់ ដោយនិយាយថាមកផឹកនៅហាងណាណា ខ្លួនបានតបទៅវិញថាផឹក សិនទៅចាំបន្តិចទៀតខ្ញុំទៅ ។ រហូតដល់ម៉ោងប្រហែល៨យប់ជាង ខ្លួនក៏ចេញពីបន្ទប់ខារ៉ាអូខេ ហើយជិះម៉ូតូឌុបដើម្បីមកជួបឈ្មោះថាតនៅហាងណាណា ពេលមកដល់ឈ្មោះថាតបានយកលុយពីខ្លួនចំនួន៦០.០០០( ប្រាំមួយម៉ឺនរៀល) ហើយឱ្យខ្លួនចាំនៅក្រៅហាង ដោយចាំយូរពេកខ្លួនក៏តេទូរស័ព្ទទៅសួរ ព្រោះពេលនោះម៉ោង៩ទៅហើយ ។មួយសន្ទុះក្រោយមកឈ្មោះថាតក៏ចេញមកក្រៅ ហើយក៏នាំគ្នាជិះម៉ូតូត្រឡប់ទៅផ្ទះជួលឈ្មោះថាត ពេលមកដល់មុខរបងផ្ទះជួលឈ្មោះថាតក៏ចុះទៅបើកទ្វាររបង ហើយដើរទៅចាក់សោរបន្ទប់ ឯខ្លួនជាអ្នកបណ្ដើរម៉ូតូចូលទៅក្នុងបន្ទប់របស់គាត់ខ្លួនក៏លាឈ្មោះថាតទៅផ្ទះវិញ ហើយនិយាយប្រាប់គាត់ថា អត់បានដេកជាមួយទេ ខ្ញុំទៅភ្នំពេញហើយបន្ទាប់មកខ្លួនក៏ដើរឡើងមកលើផ្លូវ ហើយហៅម៉ូតូឌុបជិះមកនាគព័ន្ធដើម្បីរកឡានជិះទៅផ្ទះឪពុករបស់ខ្លួននៅភ្នំពេញព្រោះខ្លួនត្រូវឱ្យគាត់ជូនទៅមន្ទីរពេទ្យដើម្បីពិនិត្យជំងឺគ្រុនចាញ់ និងរលាកថ្លើម ។ ពេលខ្លួនចេញដំណើរទៅភ្នំពេញជិះរថយន្តក្ងូរ៉េធុនតូចដោយគេយកថ្លៃ២០.០០០រៀល គឺជិះតាមផ្លូវព្រែកក្ដាមហើយបានចុះនៅគល់ស្ពានជ្រោយចង្វាហៅម៉ូតូឌុបជិះបន្តទៅផ្ទះឪពុកម្ដាយនៅឫស្សីកែវអស់ប្រាក់៥.០០០រៀលទៀត។ ពេលដល់នៅម៉ោង១២យប់ជាងខ្លួនបានទូរស័ព្ទហៅម្ដាយអោយបើកទ្វារអោយ តែគាត់មិនលើកខ្លួនក៏ចុចកណ្ដឹងទើបម្ដាយគាត់បើកទ្វារអោយខ្លួនចូលដល់ផ្ទះមានម្ដាយចាំទទួល ពេលនោះឪពុកសួរថា មកធ្វើអ្វីទាំងយប់ ខ្លួនថាជម្ងឺគ្រុនចាញ់ខ្ញុំរើឡើងវិញហើយហើយក៏សំរាកតែម្ដងទៅ ។ លុះដល់ម៉ោង៥ទៀបភ្លឺខ្លួនបានទូរស័ព្ទហៅម្ដាយអោយបើកទ្វារផ្ទះ ព្រោះខ្លួនចេញទៅរកផឹកកាហ្វេនៅផ្សារ ។ លុះព្រឹកឡើងនៅថ្ងៃទី១០-០២-២០១៤ខ្លួនបានទូរស័ព្ទសុំច្បាប់មេឈប់សម្រាក ខ្លួនមិនបានតេទាក់ទងទៅឈ្មោះថាតទេ ។ នៅថ្ងៃទី១១-០២-២០១៤ វេលាម៉ោងប្រហែល៩ព្រឹកខ្លួនបានទៅពិនិត្យជម្ងឺនៅមន្ទីរពេទ្យលោកសង្ឃ( មន្ទីរពេទ្យព្រះកុសុមៈ) ជាមួយឪពុក ពេលនោះពេទ្យមិននៅពេទ្យណាត់អោយថតនៅថ្ងៃទី១៣-០២-២០១៤។ ពេលពិនិត្យរួចហើយ នៅម៉ោង២ថ្ងៃទី១៣-០២-២០១៤ ខ្លួនក៏ធ្វើដំណើរទៅដីចំការរបស់ឪពុកនៅខេត្តក្រចេះ កាត់តាមកំពង់ចាមដោយពុំបានចូលកន្លែងធ្វើការទេ គឺទៅចាំចំការនិងនៅព្យាបាលជម្ងឺ ។ នៅវេលាម៉ោង១ថ្ងៃត្រង់ថ្ងៃទី១៤-០២-២០១៤ ខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួនខ្ញុំតែម្ដង ។ ក្នុងពេលដែលសមត្ថកិច្ចឃាត់ខ្លួននោះ គឺបាន ដកហូតលុយដុល្លារចំនួន៥ ០០$ ( ប្រាំរយដុល្លារអាមេរិក) និងទូរស័ព្ទដៃចំនួន០២គ្រឿង គឺមានម៉ាកណូគាចុចពិលពណ៌ខ្មៅ០១គ្រឿង និងពណ៌ក្រហម០១គ្រឿង ។ ចំពោះលុយចំនួន៥.០០$( ប្រាំរយដុល្លារ

អាមេរិក) ដែលមាននេះ គឺខ្លួនបានខ្ចីពីប្រពន្ធឈ្មោះតារា និប្រពន្ធឈ្មោះ[redacted] កុសល ហើយខ្លួនរក្សាវាទុកក្នុងសៀវភៅនៅផ្ទះស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ដោយខ្លួនបានឱ្យឪពុកខ្លួនទៅយកសៀវភៅចំនួន០៣ក្បាល និងបញ្ជូនឯកសារ០២ស៊ីមីទុកឱ្យប្រធានការិយាល័យឈ្មោ[redacted]រ៉ា តាមរយៈឈ្មោះ[redacted]សុផាត កាលពីថ្ងៃទី១២-០២-២០១៤។ ខ្លួនស្គាល់ឈ្មោះថាត រយៈពេលជាង៨ឆ្នាំហើយ មិនដែលឃើញឈ្មោះថាត មានពាក់ខ្សែកទេឬមានពាក់ជញ្ចៀនមាសទេ។ ខ្លួនប្រើទូរស័ព្ទ២ខ្សែគឺមានលេខ០១២ ៤១ ៧៨ ៧០និង០៨៨ ៥៣៣ ៥៣៣១ហើយឪពុកម្តាយខ្លួនមានលេខ០៩៩ ៤១ ៧៨ ៧០ . ០៩៧ ៧៤១ ៧៨ ៧០ និង០១២ ៣៦ ៩៨ ៩៦ ។ ចំណែកលេខទូរស័ព្ទរបស់ឈ្មោះថាត មានពីរខ្សែដែរ គឺ០១១ និង០៩៩ តែខ្លួនមិនចាំលេខកន្ទុយឡើយ ។ ក្នុងរឿងនេះខ្លួនមិនបានសម្លាប់ឈ្មោះថាតទេ សូមតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យរូបខ្លួន និងសុំដោះលែងអោយមានសេរីភាពវិញ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]វល័ក្ខណ៍ បានឆ្លើយថា ខ្លួនត្រូវជាកូនបង្កើតរបស់ឈ្មោះថាត ដែលជាជនរងគ្រោះ។ មុនពេលកើតហេតុឪពុកខ្លួនឈ្មោះ[redacted]សាថាតដែលជាមន្ត្រីធនាគារជាតិកម្ពុជានៅខេត្តកំពង់ចាម គាត់ស្នាក់នៅផ្ទះជួលក្នុងក្រុងកំពង់ចាមនេះ ប៉ុន្តែខ្លួនមិនដឹងថានៅម្តុំណាទេ។ អោយតែរាល់ចុងសប្តាហ៍គឺល្ងាចថ្ងៃសុក្រគាត់តែងតែទៅផ្ទះនៅស្រុកព្រៃឈរ។ កន្លងមកនៅមុនកើតហេតុឪពុកខ្លួនពាក់ខ្សែកមាសទម្ងន់ជាង១តំឡឹង និងមានប្រាក់ចំនួន៣.០០០ដុល្លារអាមេរិក។ នៅយប់ថ្ងៃទី១០-០២-២០១៤វេលាម៉ោងប្រហែល១រំលងអាធ្រាតប្អូនប្រុសរបស់ខ្លួន បានតេទូរស័ព្ទមកប្រាប់ខ្លួនថា ប៉ាត្រូវភ្លើងឆេះនៅកំពង់ចាម ពេលទទួលបានដំណឹងភ្លាម ខ្លួនក៏ជិះរថយន្ត ពីធនាគារអេស៊ីលីដាប្រចាំនៅស្រុកពញាក្រែកមកកំពង់ចាម ពេលដល់មន្ទីរពេទ្យក៏ឃើញឪពុកខ្លួនមានរបួសធ្ងន់ដោយភ្លើងឆេះ ហើយខ្លួនក៏បញ្ជូនគាត់ទៅមន្ទីរពេទ្យភ្នំពេញតែម្តង។ ពេលទៅដល់មន្ទីរពេទ្យលោកសង្ឃភ្លាម ពេទ្យចាប់ផ្តើមសង្គ្រោះគាត់ដោយចាក់ថ្នាំចំនួន០២ម្ជុល រហូតដល់ម៉ោង៥ទៀបភ្លឺពេទ្យបានប្រាប់ថាឪពុកខ្លួនស្លាប់បាត់ហើយ។ ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណងជូសជុលការអន្តរាយ និងជម្ងឺចិត្តពីជនជាប់ចោទជាប្រាក់ចំនួន១០០.០០០$( មួយរយពាន់ ដុល្លារអាមេរិក) ។

តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]**គឹមស្រ៊ី** បានបញ្ជាក់ថា នៅថ្ងៃខែមិនចាំឆ្នាំ២០១៤ វេលាម៉ោង១១យប់ ប្រពន្ធខ្លួនបានដាស់ខ្លួនថា ភ្លើងឆេះផ្ទះ ឮដូច្នេះខ្លួនក៏ងើបឡើងស្ទុះទៅរកទុយោទឹកមកបាញ់ពន្លត់ភ្លើង ពេលដែលកំពុងបាញ់ពន្លត់ភ្លើងជិតរលត់ក្នុងបន្ទប់លេខ៦ ខ្លួនក៏ឃើញជនរងគ្រោះ រៀរចេញពីក្នុងបន្ទប់ទឹក ហើយត្រូវភ្លើងឆេះពេញខ្លួន បន្ទាប់មកខ្លួននិងកូនប្រុសព្រមទាំងអ្នកជិតខាង បាននាំគ្នាជួយលើកជនរងគ្រោះដាក់លើម៉ូតូដើម្បីយកមកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាម។ រឿងហេតុដំបូងនៃការបង្កនាំកើតមានភ្លើងឆេះនោះខ្លួនពុំបានដឹងទេ ព្រោះពេលនោះខ្លួនកំពុងតែដេកលង់លក់។ ក្នុងរឿងនេះខ្លួនបានប្តឹងជនដែលបង្កឱ្យខូចខាតទ្រព្យសម្បត្តិរបស់ខ្លួនកាលពីដំបូង ប៉ុន្តែពេលនេះខ្លួនឈប់ប្តឹងទាមទារសំណង ដោយគ្រាន់តែសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ចុះ ។

សាក្សីដោះបន្ទុកឈ្មោ[redacted]**ប៊ុនថៃ**បានឆ្លើយថា ខ្លួនជាឪពុកបង្កើតរបស់ឈ្មោះ[redacted]ម៉ារ៉ែនកន្លងមកកូនរបស់ខ្លួនជាមនុស្សស្លូតបូត ជាមនុស្សរៀនចេះដឹងណាស់ ចំពោះការចោទប្រកាន់មកលើកូនប្រុសរបស់ខ្លួន គឺវាមិនពិតនោះទេព្រោះថានៅថ្ងៃទី០៩-០២-២០១៤នៅម៉ោងជិត១២យប់គឺកូនរបស់ខ្លួនចុចកណ្តឹងហៅម៉ាក់ប៉ាបើកទ្វារអោយ រីឯខ្លួនក៏ចុះមកបើកទ្វារ ហើយសួរវាថា កូនឯងមកមានការអី? ឈ្មោះ[redacted]ម៉ារ៉ែន ឆ្លើយថាជំងឺគ្រុនចាញ់របស់ខ្ញុំរើវិញហើយ ខ្ញុំសុំច្បាប់មេហើយ ដោយប្រាប់មេថា សុំមកមើលជំងឺនៅភ្នំពេញ។ លុះព្រឹកឡើងខ្លួនក៏ទិញថ្នាំគ្រុនចាញ់ឱ្យវាហូប តែមិនបាត់ទេនៅតែក្តៅដដែល។ នៅថ្ងៃទី១១-០២-២០១៤ខ្លួនក៏ជូនកូនទៅមន្ទីរពេទ្យលោកសង្ឃ ហើយពេទ្យក៏បានបញ្ជាក់ផងដែរថា ជំងឺគ្រុនចាញ់នេះពិតជារើឡើងវិញមែននិងឈានចូលដល់ការិតអេប៉ូទីតបេ រួចពេទ្យក៏ចេញសំបុត្រឱ្យទិញថ្នាំលេប។ លុះដល់ម៉ោង២-៣រសៀលថ្ងៃដដែល វាក៏សុំខ្លួនទៅមើលផ្ទះនៅខេត្តក្រចេះ ភូមិសំបូរសែនជ័យ ឃុំស្វាយជ្រះ ស្រុកស្នួលដែលជាផ្ទះរដ្ឋចែកឱ្យខ្លួន។ ពេលនោះខ្លួនក៏ឱ្យវាទៅ ស្រោប់

តែនៅថ្ងៃទី១៤-០២-២០១៤ កូនរបស់ខ្លួនបានទូរស័ព្ទមកប្រាប់ខ្លួនថាវាត្រូវប៉ូលីសចាប់ខ្លួន ហើយខ្លួនក៏សួរវិញថា កូនឯងមានរឿងអីបានជាគេចាប់ វាតបវិញថា ប៉ាកុំសួរអី ព្រោះខ្ញុំទូរស័ព្ទប៉ូលីសនិយាយ ហើយវាគ្រាន់តែនិយាយថាបើប៉ាចង់ដឹងច្បាស់ ប៉ាមកជួបកូននៅស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ។

សាក្សីឈ្មោះ[redacted] **តារ៉ា** បានឆ្លើយបំភ្លឺថា នៅថ្ងៃកើតហេតុនោះ ខ្លួនពុំបានចាំថ្ងៃខែឆ្នាំទេ មុនដំបូងឈ្មោះ[redacted] ម៉ារ៉ែន បាននិយាយជាមួយខ្លួនថា នៅហាងស៊ុបភើខូល មានស្រីស្អាត១ច្រើន ខ្លួនក៏និយាយថា អញ្ជើងរ៉ៃគ្នាទៅ ប្រហែល៤-៥ម៉ឺន ចូលបានហើយ ។ ពេលនិយាយចប់ក៏ត្រូវរ៉ៃគ្នា ដោយនាំគ្នាទៅមានគ្នា០៣នាក់ ដែលមានឈ្មោ[redacted]កុសល .ឈ្មោ[redacted]ម៉ារ៉ែន និងរូបខ្លួនផ្ទាល់ ។ ពេលទៅដល់ហាងស៊ុបភើខូល ក៏នាំគ្នាផឹកស៊ីដល់ម៉ោងប្រហែល៦ល្ងាច ក៏ជជែកគ្នាថាបន្តទៅច្រៀងនៅខារ៉ាអូខេ ABC KTV ទៀត ដោយខ្លួនជាអ្នកធានាចេញម៉ោងឱ្យពួកគេជាអ្នកចេញស្រានិងសាច់ក្លែម ។ ពេលទៅដល់ខ្លួនក៏បានឱ្យគេរៀបចំបន្ទប់ ហើយឈ្មោះ[redacted]ម៉ារ៉ែន បានតេទូរស័ព្ទហៅកូនចៅរបស់គេម្នាក់ទៀត ឈ្មោះឆេះ សំបុរខ្មៅឱ្យមកចូលរួមដែរ ចំណែកខ្លួនពេលនោះពុំសូវផឹកទេ ព្រោះជាប់រវល់ដើរមើលភ្ញៀវ ដោយកន្លែងខារ៉ាអូខេ ABC KTV ខ្លួនជាអ្នកគ្រប់គ្រង ។ ខ្លួនឧស្សាហ៍ឃើញឈ្មោះ[redacted]ម៉ារ៉ែន ចេញក្រៅបន្ទប់ច្រៀង មកនិយាយទូរស័ព្ទណាស់ ប៉ុន្តែមិនដឹងថានិយាយជាមួយអ្នកណាទេ ហើយនិយាយពីរឿងអ្វីដែរ ។ ពេលច្រៀងចប់ម៉ោងប្រហែលជិត៩យប់ ខ្លួនឃើញឈ្មោ[redacted] ម៉ារ៉ែន គិតលុយហើយក៏ចេញទៅបាត់ទៅ តែខ្លួនមិនបានដឹងថាទៅជាមួយនរណាទេ ព្រោះជាប់រវល់មើលភ្ញៀវនៅហាង ។

សាក្សីឈ្មោះ[redacted]**កុសល្យ** បានឆ្លើយថានៅថ្ងៃកើតហេតុទី០៩-០២-២០១៤វេលាម៉ោងប្រហែល៤រសៀលឈ្មោះ[redacted]តារ៉ា និងឈ្មោះ[redacted]ម៉ារ៉ែនបានបបួលខ្លួនទៅផឹកនៅហាងស៊ុបភើខូល ម៉ុំនាងគង្ហឹង ដោយជិះម៉ូតូ០២គ្រឿង ខ្លួនជាអ្នកឌុបឈ្មោះ[redacted] ម៉ារ៉ែន ពេលទៅដល់ក៏នាំគ្នាផឹករហូតដល់ម៉ោង៦ល្ងាចក៏ឈប់ផឹក ក្រោយមកឈ្មោ[redacted]តារ៉ា បានបបួលទៅច្រៀងនៅខារ៉ាអូខេABC KTV ពេលទៅដល់ខ្លួនឱ្យមេកាហៅស្រីម្នាក់មកអង្គុយក្បែរ ហើយក៏នាំគ្នាផឹកស៊ីក្នុងបន្ទប់ខារ៉ាអូខេនោះទៅ ប៉ុន្តែពេលកំពុងផឹក ខ្លួនឃើញឈ្មោះ[redacted]ម៉ារ៉ែន អង្គុយពុំជាប់លាប់ទេរវល់តែដើរចុះឡើង ហើយខ្លួនឃើញគាត់តេទូរស័ព្ទហៅឈ្មោះ[redacted]សុខសល់មកផឹកដែរ មួយសន្ទុះក្រោយមកក៏ឃើញឈ្មោ[redacted] សុខសល់មកដល់ ហើយនាំគ្នាផឹកបន្តរហូតដល់ម៉ោងប្រហែល៨យប់ជាង ទើបគិតលុយចេញ ហើយឈ្មោះ[redacted]សុខសល់ក៏បបួលទៅហូបស៊ុបនៅហាងកូនរាជ ទៀត ប៉ុន្តែឈ្មោះ[redacted]ម៉ារ៉ែន មិនទៅទេ ខ្លួនសួរទៀតថា ឯងទៅណាទៀត បើទៅដេកនៅកន្លែង ចាំអញជូនទៅ វាឆ្លើយថាខ្ញុំអត់ទៅទេបង មិនអីទេបងឯងទៅផ្ទះចុះ ព្រោះបន្តិចទៀតខ្ញុំមានគេមកយកហើយ ឮដូច្នេះខ្លួនក៏ជិះម៉ូតូចេញទៅមុន។

សាក្សីដោះបន្ទុកឈ្មោ[redacted] **ផុំ** បានឆ្លើយបំភ្លឺថា កន្លងមកឈ្មោះ[redacted] ម៉ារ៉ែន តែងតែទៅលេងផ្ទះឪពុកបង្កើតរបស់គាត់ឈ្មោះ[redacted] ប៊ុនថៃដែលផ្ទះនិងដីនោះរដ្ឋជាអ្នកចែកឱ្យ ។ នៅមុនគេចាប់ខ្លួ[redacted]ម៉ារ៉ែន ខ្លួនបានឃើញឈ្មោ[redacted]ម៉ារ៉ែន នៅផឹកកាហ្វេ ដោយឈ្មោះនេះបង្ហាញខ្លួនជាសាធារណៈដោយមិនមានសភាព ភិតភ័យអ្វីទេ ព្រមទាំងជជែកគ្នាជាមួយមិត្តភក្ត្រ័ជាច្រើននាក់ ស្រាប់តែពេលរសៀលឮគេថាសមត្ថកិច្ចមកចាប់ ខ្លួនឈ្មោះ[redacted]ម៉ារ៉ែនតែម្តង ។ កន្លងមកឈ្មោះ[redacted]ម៉ារ៉ែនធ្វើជាប៉ូលីសនៅខេត្តកំពង់ចាម គាត់ជាមនុស្សសុភាពរាបសារស្លូតបូត ពេលគាត់មកលេងផ្ទះឪពុករបស់គាត់ម្តង១ តែងតែប្រាប់ខ្លួនជាអនុប្រធានភូមិរហូត ។ មុនពេលខ្លួនជួបឈ្មោះ[redacted]ម៉ារ៉ែន នោះវាបាននិយាយប្រាប់ខ្លួនដែរថា វាមានជម្ងឺលាប់គ្រុនចាញ់ ប្រតិកម្មថ្នាំ ត្រូវការសំរាក០១រយៈ ដើម្បីព្យាបាលអោយជាឡើងវិញ និងម៉្យាងនៅមើលថែទាំដំណាំនិងផ្ទះឪពុកផង ។

សាក្សីដោះបន្ទុកឈ្មោ[redacted] **ប៊ុនគង់** បានឆ្លើយថានៅមុនពេលគេចាប់ខ្លួនឈ្មោះ[redacted]ារ៉ែន នៅផ្ទះគាត់ដែលនៅភូមិសំបូរសែនជ័យ ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ហើយពេលនោះខ្លួនក៏បានសួរថា ម៉ារ៉ែនឯងមកមានការអី?វាឆ្លើយថាខ្ញុំមកដើម្បីព្យាបាលជំងឺគ្រុនចាញ់ព្រោះតែមានអាការៈលាប់នឹងប្រតិកម្មថ្នាំ ហើយខ្លួនក៏សួរ

ទៀតថារួចមានការអីទៀត វាក៏ឆ្លើយថាសុំពឹងពាក់បងឱ្យជួយរកជាងដូរគន្លឹះបង្អួច និងជួយរកកម្មករបាញ់ថ្នាំសំលាប់ស្បូវ ។ លុះដល់ម៉ោងប្រហែល ១រសៀល ឈ្មោះម៉ារ៉ែន បានឱ្យខ្លួនឌុបទៅទិញថ្នាំបាញ់ស្បូវនៅភូមិរលួច ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះពេលនោះពួកខ្លួនជិះបានចម្ងាយប្រហែលជា២គីឡូម៉ែត្រ ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួនតែម្តង គឺឃាត់ខ្លួននៅចំណុចសាលាបឋមសិក្សាអន្លង់កេះ ។ ចំពោះការឃាត់ខ្លួនឈ្មោះ[redacted]ម៉ារ៉ែន ខ្លួនពុំបានសួរនាំប៉ូលីសថាឃាត់ពីរឿងអ្វីទេ ។ កន្លងមកខ្លួនមានទំនាក់ទំនងជាមួយឈ្មោ[redacted]ម៉ារ៉ែនដោយសារតែគាត់ធ្លាប់ធ្វើជាមេរបស់ខ្លួន គាត់មានអត្តចរិកល្អ ស្លូតបូតសុភាពរាបសារ និងជាអ្នករៀនចេះដឹងខ្ពង់ខ្ពស់ទៀត ។

តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] បុប្ផា បានបញ្ជាក់ថា មុនពេលកើតហេតុ នៅវេលាម៉ោងប្រហែល ៩យប់ថ្ងៃទី០៩-០២-២០១៤ ខ្លួនបានចុះមកចាក់សោររបង ដើម្បីចេញយកឯកសារទៅផ្ញើគេ ពេលដែលខ្លួនចាក់សោររបងរួច ខ្លួនឃើញជនរងគ្រោះជិះម៉ូតូម៉ាកWave ពណ៌ខ្មៅ ដោយមានមនុស្សប្រុសម្នាក់ជិះឌុបជនរងគ្រោះ ហើយចុះពីលើម៉ូតូបណ្តើរចូលទៅក្នុងបន្ទប់កើតហេតុ ។ ពេលនោះខ្លួនក៏ប្រាប់ទៅជនរងគ្រោះថា ពូជួយគីបសោរផង ហើយខ្លួនក៏ជិះម៉ូតូចេញទៅយកឯកសារឱ្យគេ បន្ទាប់ពីយកឯកសារឱ្យគេហើយខ្លួនក៏ត្រឡប់មកផ្ទះវិញ ដោយចាក់សោររបងផ្ទះត្រឹមត្រូវរួចក៏ចូលទៅសំរាកក្នុងបន្ទប់របស់ខ្លួន ។ មួយសន្ទុះក្រោយមកស្រាប់តែឮសំឡេងស្រែកឆោឡោឡើង ខ្លួនក៏ក្រោកមើល ។ ភ្លាមនោះខ្លួនឃើញភ្លើងឆេះនៅក្នុងបន្ទប់របស់ជនរងគ្រោះ ខ្លួនក៏ស្ទុះចេញមកជួយពន្លត់ភ្លើង ព្រមទាំងឃើញម្ចាស់បន្ទប់រងរបួសដោយសារភ្លើងឆេះ ប៉ុន្តែម្នាក់ដែលមកជាមួយជនរងគ្រោះមុនពេលកើតហេតុនោះ មិនមានវត្តមាននៅក្នុងបន្ទប់កើតហេតុនោះទេ ហើយក៏មិនដឹងចេញទៅតាំងពីពេលណាមកដែរ ។

តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] ស្រីមុំ បានបញ្ជាក់ថា នៅមុនពេលកើតហេតុជនរងគ្រោះបានមកជួលបន្ទប់លេខ៦នេះ ទើបតែបានចំនួន ៥ថ្ងៃប៉ុណ្ណោះក៏កើតរឿងនេះឡើងតែម្តង ។ ខ្លួនបានជួលបន្ទប់ឱ្យជនរងគ្រោះស្នាក់នៅក្នុងតម្លៃ៧៥$(សាបសិបប្រាំដុល្លារអាមេរិក) ក្នុង០១ខែ ។ នៅមុនកើតហេតុ០១ថ្ងៃគឺជាថ្ងៃសៅរ៍ខ្លួនបានឃើញជនរងគ្រោះឈ្មោះថាត គាត់បានឌុបមិត្តភ័ក្រ្ត០១នាក់មិនស្គាល់ឈ្មោះ ចូលមកសំរាកនៅបន្ទប់លេខ៦របស់គាត់វេលាម៉ោងប្រហែល១០យប់ ។ នៅក្នុងពេលកើតហេតុនោះ ខ្លួនបានឮសំឡេងផ្ទុះឮសូរផេស១ នៅម៉ោង១១យប់ខ្លួនក៏ស្ទុះងើបឡើង ហើយឃើញផ្សែងហុយចេញពីបន្ទប់លេខ៦និងមានអណ្តាតភ្លើង ភ្លាមនោះខ្លួនបានឃើញមនុស្សប្រុស០១នាក់ រត់ចេញពីក្នុងបន្ទប់លេខ៦ រត់សំដៅទៅមុខទ្វារផ្ទះ ពេលនោះខ្លួនមិនចាំភិនភាគមនុស្ស០១នាក់នោះទេ ព្រោះភ័យរឿងភ្លើងឆេះក្នុងបន្ទប់លេខ៦ ។ បន្ទាប់មកខ្លួនក៏ស្រែកដាស់ប្តីខ្លួនឱ្យជួយ ភ្លាមនោះប្តីរបស់ខ្លួនក៏ស្ទុះងើបឡើង រត់ទៅទាញទុយោបាញ់ទឹកយកមកបាញ់ពន្លត់ភ្លើង រីឯកូនប្រុសរបស់ខ្លួនបានរត់ទៅយកបំពង់ពន្លត់អគ្គីភ័យ រួមទាំងអ្នកជិតខាងក៏នាំគ្នាចេញមកជួយ ទើបពន្លត់ភ្លើងរលត់ ។ ពេលនោះខ្លួនឃើញជនរងគ្រោះត្រូវភ្លើងឆេះពេញខ្លួន ព្រោះជនរងគ្រោះរៀវចេញពីបន្ទប់ទឹកមក ក្រោយមកប្តីខ្លួននិងកូនព្រមទាំងអ្នកជិតខាងជួយលើកជនរងគ្រោះដាក់លើម៉ូតូ ដឹកយកទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្តកំពង់ចាម ។

តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] វិចិត្រ បានបញ្ជាក់ថានៅថ្ងៃទី០៩-០២-២០១៤វេលាម៉ោងប្រហែល ១០យប់ ខ្លួនឮសំឡេងហៅឈ្មោះថាតឱ្យបើកទ្វាររបង បន្ទាប់មកឃើញបើកទ្វារ ហើយឮសំឡេងម៉ូតូជិះចេញ តែខ្លួនមិនបានចាប់អារម្មណ៍ថាមានគ្នាប៉ុន្មាននាក់ទេ ។ លុះដល់ម៉ោងប្រហែល១១យប់ ស្រាប់តែខ្លួនភ្ញាក់ឡើងឃើញភ្លើងឆេះពេញបន្ទប់ក្រោមផ្ទះ ពេលនោះខ្លួនក៏ស្ទុះចុះទៅជាមួយឪពុករបស់ខ្លួនឈ្មោះ[redacted]គឹមស្រ៊ុទាញទុយោបាញ់ទឹកពន្លត់ ស្រាប់តែឃើញមនុស្សប្រុសរត់ចេញពីក្នុងបន្ទប់មកក្រៅ ទើបខ្លួនដឹងថាជាឈ្មោ[redacted]សាថាត ភ្លើងឆេះខ្លួន ក៏ដឹកគាត់ទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់ ហើយជិះម៉ូតូទៅកន្លែងឈ្មោ[redacted]សាថាត ធ្វើការ ដើម្បីឱ្យគេជួយតេរកបងប្អូនរបស់គាត់ ។ ក្រោយមកខ្លួនក៏ត្រឡប់មកមន្ទីរពេទ្យវិញ នៅជួយមើលឈ្មោ[redacted] សាថាតរហូតដល់ម៉ោង

ប្រហែល២យប់ ពេទ្យក៏បានបញ្ជូនឈ្មោះថាត ទៅសង្គ្រោះនៅភ្នំពេញ ។ ក្រោយមកទៀតខ្លួនក៏បានជិះម៉ូតូមកផ្ទះជាមួយនគរបាល ដើម្បីមកធ្វើកំណត់ហេតុផ្សេងៗ នៅនឹងកន្លែងកើតហេតុផ្ទះរបស់ខ្លួន ។

តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] ហួរ បានបញ្ជាក់ថាមុនពេលកើតហេតុថ្ងៃទី០៩-០២-២០១៤វេលាម៉ោង៦ល្ងាច ខ្លួនបានចូលសំរាកនៅក្នុងបន្ទប់លេខ៣ រហូតដល់ម៉ោងប្រហែល១១យប់ ខ្លួនក៏ដេកលក់បន្តិចស្រាប់តែឮសំឡេងម្ចាស់ផ្ទះស្រែក ហើយធុំក្លិនឈ្ងៀម ខ្លួនក៏ចេញមកមើលឃើញអណ្តាតភ្លើងកំពុងតែឆេះចេញពីក្នុងបន្ទប់លេខ៦ ខ្លួន និងម្ចាស់ផ្ទះក៏នាំគ្នាជួយពន្លត់ ហើយឃើញមានមនុស្សប្រុសម្នាក់វារចេញពីក្នុងបន្ទប់ ដោយក្នុងសភាពត្រូវភ្លើងឆេះអស់ខោអាវនៅខ្លួនទទេ រីឯនៅនឹងខ្លួនក៏ពុំមានរបស់របរអ្វីដែរ ខ្លួននឹងម្ចាស់ផ្ទះក៏ចូលទៅគ្រាចេញមកក្រៅ ហើយតេទូរស័ព្ទរកឡានពេទ្យ តែគ្មានឡានពេទ្យ ភ្លាមនោះខ្លួននិងកូនម្ចាស់ផ្ទះក៏នាំគ្នាឌុបយកជនរងគ្រោះទៅមន្ទីរពេទ្យ ពេលទៅដល់ពេទ្យខ្លួនក៏ឃើញមានសមត្ថកិច្ចមកដល់ ។

តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] ពិសី ហៅ តី បានបញ្ជាក់ថា នៅថ្ងៃទី០៩-០២-២០១៤ វេលាម៉ោង៨.៣០នាទីយប់ ឈ្មោះថាតបានមកផឹកស្រានៅហាងណាណាម្នាក់ឯង តែពេលគាត់មកដល់នៅខាងមុខហាងគឺមានគេជូនមក តែខ្លួនមិនស្គាល់ម្នាក់នោះទេគ្រាន់តែដឹងថាម៉ូតូដែលជិះនោះជាម៉ូតូរបស់ឈ្មោះថាត ក្រោយពេលចូលដល់ក្នុងហាង គាត់ផឹកស្រាបៀរកម្ពុជានៅក្នុងកញ្ចះរតនគីរី រហូតដល់ម៉ោង៩យប់ ទើបគាត់ឈប់ផឹក ។ ពេលគាត់ចេញទៅគាត់បានតេខ្ចីលុយ អ្នកដែលយកម៉ូតូគាត់ជិះ ដើម្បីឱ្យថ្លៃផឹកស៊ី និងហៅឱ្យមកយកគាត់នៅហាងណាណា ។ អ្នកដែលមកយកគាត់ក៏ឈប់ម៉ូតូនៅខាងមុខហាង ហើយគាត់ក៏ដើរចេញទៅបាត់ទៅ ។

តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] តុលា បានឆ្លើយបំភ្លឺថា កាលពីថ្ងៃទី០៨-០២-២០១៤ វេលាម៉ោងប្រហែលជាង៨យប់ជាង ខ្លួនបានឃើញមនុស្សប្រុសម្នាក់អាយុប្រហែល៥០ជាង គាត់ធ្លាប់និយាយប្រាប់ខ្លួនថាគាត់ធ្វើការនៅធនាគារជាតិនៃកម្ពុជា នៅពេលនោះគាត់បានអង្គុយផឹកជាមួយបុរសម្នាក់ទៀតមិនស្គាល់ឈ្មោះដែលមានរាងស្គមខ្ពស់ សម្បុរស ស្លៀកពាក់ខោខ្មៅជើងវែង អាវខ្មៅដៃវែង ពួកគាត់អង្គុយផឹកបាន០១សន្ទុះក៏ចេញទៅវិញបាត់ទៅ ។ លុះដល់ថ្ងៃទី០៩-០២-២០១៤ វេលាម៉ោងប្រហែលជា៩ជាង ខ្លួនបានឃើញគាត់ដែលធ្វើការនៅធនាគារជាតិនៃកម្ពុជាមកផឹកម្តងទៀតនៅកញ្ចះរតនគីរី ប៉ុន្តែពេលផឹកបានមួយសន្ទុះគាត់ក៏ចេញទៅវិញបាត់ ។

តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] លី បានបញ្ជាក់ថា នៅម៉ោងប្រហែលជា៩ជាង ខ្លួនបានឃើញបុរសម្នាក់ជិះម៉ូតូម៉ាកវ៉េវហាល់ហ្វាឌុបពូថាតមកចុះនៅមុខហាងណាណា ហើយជិះម៉ូតូចេញទៅវិញបាត់ទៅ រីឯពូថាតគាត់ដើរចូលមកផឹកក្នុងហាង ដោយផឹកស្រាបៀរកម្ពុជា០១យូរនិងសាច់០១ចាន អង្គុយហូបនៅនឹងតុ០១តែម្នាក់ឯង ពេលកំពុងតែអង្គុយហូប គាត់និយាយអួតប្រាប់អ្នកដែលនៅក្នុងហាងថាគាត់ធ្វើការនៅធនាគារ ហើយថែមទាំងយកដៃបកកអាវរបស់គាត់ បង្ហាញខ្សែកមាស ដល់គេឯងក្នុងហាង ដោយប្រាប់គេថាខ្សែកគាត់នេះ ធ្វើជិត២តម្លឹងមាស អួតរួចគាត់ហៅគេឱ្យមកគិតលុយគឺអស់៦០.០០០(ប្រាំមួយម៉ឺនរៀល) តែគាត់គ្មានលុយទេ រួចគាត់ក៏តេទូរស័ព្ទទៅ ហៅអ្នកដែលមកឌុបគាត់មកនោះយកលុយមកអោយ ។ ក្រោយមកម្នាក់នោះក៏ជិះម៉ូតូយកលុយមកអោយមែន ហើយគាត់ក៏ងើបពីកៅអីដើរទៅយកលុយពីម្នាក់នោះមកឱ្យអ្នកលក់ រួចក៏ជិះម៉ូតូចេញទៅ ។

តាមអំណានចម្លើយសាក្សីឈ្មោ[redacted]សុផាត បានបញ្ជាក់ថា នៅថ្ងៃទី១២-០២-២០១៤ វេលាម៉ោង១៨.៣០នាទីឈ្មោះ[redacted]នថៃ ភេទប្រុសអាយុ៦៧ឆ្នាំបានទូរស័ព្ទមកសួរខ្លួនថា ឯងនៅឯណាមកជួបពូនៅរង្វង់មូលស្ពានតីហ៊្សណាបន្តិច ខ្លួនក៏បានជិះម៉ូតូមកជួបគាត់ ពេលមកដល់គាត់និយាយថា អាវ៉ែនផ្តាំថា វាមានជម្ងឺគ្រុនចាញ់ ហើយខ្លួនក៏ សួរតបវិញថា ពូឯងបានសុំច្បាប់លោកវ៉ា ដែលជាប្រធានហើយនៅ គាត់ក៏តបវិញថា សុំច្បាប់ហើយ រួចគាត់ថា អាវ៉ែនឱ្យពូយកកូនសោរមកឱ្យឯង ដើម្បីចាក់យកឯកសារប្រគល់ឱ្យឈ្មោះផាន ផលនាយផ្នែករដ្ឋបាលគណនេយ្យ បន្ទាប់មកខ្លួនក៏ជិះម៉ូតូឌុបគាត់មកផ្ទះដែលស្នាក់ក្នុងនៅស្នងការ ។ ពេលមកដល់ផ្ទះពុំមានសោរចូលខ្លួន

ក៏សួរទៅឈ្មោះឌី ភេទប្រុសដែលរស់នៅជាប់ផ្ទះជាមួយម៉ារ៉ែន ថាមានសោរបន្ទប់របស់ម៉ារ៉ែនទេ ភ្លាមនោះឈ្មោះស៊ីណាត ភេទស្រីអាយុ៣៥ឆ្នាំឆ្លើយថាខ្លួនមានកូនសោរបន្ទប់ ព្រោះគេដាក់កង់នៅទីនោះដែរ ។ ក្រោយមកឈ្មោះស៊ីណាត ក៏យកកូនសោរទៅចាក់ ហើយនាំគ្នាចូលទៅក្នុងបន្ទប់ ។ បន្ទាប់មកឈ្មោះហេង ប៊ុនថៃ ក៏យកសោរទៅចាក់ហិប របស់ឈ្មោះ[redacted]ម៉ារ៉ែន ដើម្បីយកសៀវភៅ៣ក្បាល ដែលមាន២ក្បាលជាសៀវភៅធំ និង១ក្បាលជាសៀវភៅតូច ក្នុងនោះកឃើញកាំភ្លើងខ្លី០១ដើមដែរ បន្ទាប់មកគាត់ក៏យកសៀវភៅនោះដាក់ក្នុងកូតាបរបស់គាត់ តែមិនបានយកកាំភ្លើងដែលនៅក្នុងហិបនោះទៅទេ។ បន្ទាប់មកគាត់ក៏ហុចសោរ០១ ចង្កោមមកឱ្យខ្លួនហើយឱ្យខ្លួនជូន គាត់មករកឡានជិះទៅភ្នំពេញវិញនៅរង្វង់មូលស្ពានគីហ្សូណា ។

លោក[redacted] **សុផាណា** មេធាវីការពារអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] **វល័ក្ខណ៍** បានធ្វើសេចក្តីសន្និដ្ឋានថាៈ ក្រោយពីបានស្តាប់ការសួរដេញដោលជនជាប់ចោទ ដើមបណ្តឹងនិងសាក្សី ព្រមទាំងបានសិក្សាសំណុំរឿងទាំងមូលឃើញថា ឈ្មោះ[redacted]ម៉ារ៉ែន ពិតជាបានប្រព្រឹត្តអំពើឃាតកម្មគិតទុកជាមុនប្រាកដមែន ។ព្រោះថាអ្នកដែលដើរលេងស្និទ្ធជាមួយជនរងគ្រោះមុនកើតហេតុគឺឈ្មោះ[redacted]ម៉ារ៉ែន ហើយថ្ងៃកើតហេតុនោះអ្នកដែលនៅជាមួយជនរងគ្រោះក្រោយគេបង្អស់ក៏ឈ្មោះ[redacted]ម៉ារ៉ែនដែរ គឺអ្នកទាំងពីរជិះម៉ូតូឌុបគ្នាចូលទៅផ្ទះជួលរបស់ជនរងគ្រោះនៅមុនកើតហេតុបន្តិចឆ្លៀតឱកាសជនរងគ្រោះស្រវឹង ក៏ចាក់សាំងដុតជនរងគ្រោះតែម្តងទៅ ។ម្យ៉ាងវិញទៀត បើអ្នកក្រៅផ្សេងទៀតក៏មិនអាចចូលទៅក្នុងបន្ទប់ជួលនោះបានដែរ ព្រោះបើឈ្មោះម៉ារ៉ែន ចេញមែនទ្វារផ្ទះត្រូវឈ្មោះថាត ដាក់កន្លឹះជាប់ពុំមានអ្នកណាចូលក្នុងបានទេ។ នៅយប់កើតហេតុនោះ ហេតុអ្វីបានជាហេង ម៉ារ៉ែន ទៅភ្នំពេញទាំងយប់ទាំងតក់ក្រហល់ដោយខ្លួនធ្វើនគរបាលមានឋានៈខ្ពង់ខ្ពស់ ហើយទៅស្លៀកខោខ្លីពណ៌ប្រផេះ ពាក់អាវដៃខ្លីពណ៌ក្រហម ដោយមិនបានស្លៀកសំលៀកបំពាក់អោយបានត្រឹមត្រូវ ។ បើចង់ទៅភ្នំពេញមិនពឹងមិត្តភ័ក្ត្រអោយឌុបម៉ូតូជូនទៅរករថយន្តជិះអោយបានត្រឹមត្រូវ បែរដើរតែម្នាក់ឯងពីផ្ទះមិត្តភ័ក្ត្រទៅនាគព័ន្ធរងចាំរករថយន្តជិះទៅភ្នំពេញទាំងកណ្តាលយប់អាធ្រាតដោយជិះរថយន្តទ្រុងកូរ៉េ ។ តែបើមានជម្ងឺធ្ងន់ធ្ងរ ហេតុអ្វីមិនទៅភ្នំពេញពេលថ្ងៃ ព្រោះជាថ្ងៃអាទិត្យបែរជានៅដើរលេងផឹកស៊ីសប្បាយច្រៀងរាំ ។ ហើយរហូតដល់ភ្លឺឡើងថ្ងៃទី១០-០២-២០១៤ ទៅដល់ភ្នំពេញហើយក៏មិនបានទៅពេទ្យទៀត ដល់ថ្ងៃទី១១-០២-២០១៤ ទើបថាទៅពេទ្យ ។ ជាពិសេសទៀតនោះបើជនជាប់ចោទនេះឈឺធ្ងន់មែន ហេតុអ្វីមិននៅព្យាបាលជម្ងឺនៅភ្នំពេញ បានជារត់គេចខ្លួនទៅពួនសំងំនៅចំការឯខេត្តក្រចេះរហូតដល់ថ្ងៃទី១៤-០២-២០១៤ដោយឆ្លងកាត់ខេត្តកំពង់ចាមមិនបានចូលកន្លែងខ្លួនធ្វើការ ។ រឿងនេះសូម្បីតែពតិមានល្បីទូទាំងប្រទេសថាជនរងគ្រោះត្រូវបានសម្លាប់ ក៏ឈ្មោះ[redacted] ម៉ារ៉ែនមិនអើពើសួរសុខទុក្ខមិត្តភ័ក្ត្រសោះ ។ បើតាមចម្លើយរបស់ឈ្មោះ[redacted]ម៉ារ៉ែននៅចំពោះមុខសត្ថកិច្ចឈ្មោះនេះជំពាក់ប្រាក់គេ ៦.០០០ដុល្លារ និងខ្ចីប្រាក់ប្រពន្ធមិត្តភ័ក្ត្រ៥០០ដុល្លារទៀត ។ សរុបសេចក្តីមកឃើញថាឈ្មោះ[redacted]ម៉ារ៉ែន ពិតជាបានប្លន់យកមាសប្រាក់របស់ជនរងគ្រោះ ហើយចាក់សាំងដុតសម្លាប់ដើម្បីបំបាត់ភស្តុតាង ។ ហេតុដូច្នេះសូមអោយតុលាការផ្តន្ទាទោសឈ្មោះនេះ និងសុំអោយសម្រេចលើបញ្ហាសំណងការអន្តរាយ ព្រមទាំងជម្ងឺចិត្តដល់កូនក្តីខ្ញុំទៅតាមច្បាប់ ។

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងថាៈ ថ្វីត្បិតតែឈ្មោះ[redacted]**ម៉ារ៉ែន** មិនព្រមសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួនមែន តែតាមអង្គហេតុនិងសាក្សីឆ្លើយស៊ីសង្វាក់គ្នាថាឈ្មោះនេះពិតជាបានប្រព្រឹត្តអំពើ **ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាមប្រាកដមែន ។ តំណាងអយ្យការសូមតំកល់ដីកាសន្និដ្ឋានស្ថាពរលេខ៣៣០ព.ស ចុះថ្ងៃទី២៥ខែកក្កដា ឆ្នាំ២០១៤ទុកជាបានការពេញទាំងមូល សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចសេចក្តីទៅតាមច្បាប់ចុះ ។

លោក[redacted] **រក្សា** មេធាវីការពារអោយជនជាប់ចោទឈ្មោះ[redacted] ម៉ារ៉ែន បានធ្វើសេចក្តីសន្និដ្ឋានថាៈ ឆ្លងតាមការសួរដេញដោលនេះឃើញថា កូនក្តីខ្ញុំឈ្មោះ[redacted]ម៉ារ៉ែន មិនបានប្រព្រឹត្តអំពើឃាតកម្មគិតទុកជាមុន ទៅ

លើជនរងគ្រោះនោះឡើយ ។ តាមអង្គហេតុឃើញថា កូនក្តីខ្ញុំពិតជាបានដើរលេងសប្បាយជាមួយជនរងគ្រោះមែន តែនៅយប់កើតហេតុនោះកូនក្តីខ្ញុំបានជូនជនរងគ្រោះទៅដល់ផ្ទះជួលនៅម៉ោងប្រហែល៩យប់ ហើយគាត់ដើរទៅរកម៉ូតូឌុបជិះទៅនាគព័ន្ធដើម្បីឡើងរថយន្តឈ្នួលទៅព្យាបាលជម្ងឺគ្រុនចាញ់នៅភ្នំពេញ ពេលដល់ភ្នំពេញនៅម៉ោងប្រហែល២៤យប់ ។ នៅពេលកើតហេតុម៉ោងប្រហែល២៣យប់ ពេលនោះកូនក្តីខ្ញុំនៅកំពុងធ្វើដំណើរទៅភ្នំពេញ ដូចនេះពុំមែនកូនក្តីខ្ញុំជាអ្នកប្រព្រឹត្តទេ ។ ម្យ៉ាងទៀតផ្ទះកើតហេតុជាផ្ទះជួល មានមនុស្សចេញ ចូលច្រើន មិនដឹងថាមានអ្នកណាខ្លះទេដែលចេញចូលនោះ ។ នៅពេលនេះពុំមានភស្តុតាងស៊ីសង្វាក់សម្រាប់ដាក់បន្ទុកមកលើកូនក្តីខ្ញុំឡើយ ព្រោះភស្តុតាងដែលសមត្ថកិច្ចប្រមូលបាននោះជាភស្តុតាងប្រយោលមិនអាចចោទប្រកាន់លើកូនក្តីខ្ញុំបានទេ ។ ម្យ៉ាងវិញទៀតឃើញថាជនរងគ្រោះជាពោះម៉ាយ គាត់មានទំនាក់ទំនងជាមួយស្រី១ច្រើន គាត់ហូបស្រារាល់ថ្ងៃ ហើយមិនដឹងថាមានគំនុំជាមួយអ្នកណាខ្លះទេ គឺមានភាពអាថិកំបាំង ។ ដូច្នេះតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ វិមតិសង្ស័យត្រូវបានជាផលប្រយោជន៍របស់ជនជាប់ចោទ និងតាមមាត្រា៣៥០នៃក្រមនីតិវិធីព្រហ្មទណ្ឌសុំអោយតុលាការអោយកូនក្តីខ្ញុំរួចខ្លួនពីបទចោទ ហើយសុំដោះលែងអោយកូនក្តីខ្ញុំមានសេរីភាពចាប់ពីពេលនេះតទៅ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់ចម្លើយសាក្សីដាក់បន្ទុក និងដោះបន្ទុក
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការយល់ឃើញថា

-ជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ែន** ត្រូវបានដាក់ក្រោមការពិនិត្យ ពីបទៈ **ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៤ តាមមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ ។

-នៅគ្រប់ដំណាក់កាលទាំងអស់ ជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ែន មិនបានសារភាពថា ខ្លួនបានដុតសំលាប់ជនរងគ្រោះឈ្មោះ [redacted] សាថាត កាលពីថ្ងៃទី០៩-០២-២០១៤វេលាម៉ោង១០និង៣០នាទី នៅផ្ទះជួលស្ថិតនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាមឡើយ ។

-តាមចម្លើយរបស់ជនជាប់ចោទថា នៅយប់កើតហេតុ ខ្លួនបានជូនជនរងគ្រោះទៅហូបអាហារ និងស្រាបៀរ នៅហាងណាណា ដោយខ្លួនយកម៉ូតូរបស់ជនរងគ្រោះឌុបជនរងគ្រោះទុកឱ្យហូបអីនៅទីនោះតែម្នាក់ឯង ។ ឯខ្លួនទៅហូបអាហារនៅហាងស៊ុបភើខូល ហើយបន្តទៅច្រៀងខារ៉ាអូខេនៅABC KTV ជាមួយមិត្តភ័ក្រ្តឈ្មោះចាន់ តារ៉ានិងឈ្មោះ [redacted] កុសល្យ ។ នៅម៉ោងប្រហែល៩យប់ជនជាប់ចោទបានយកម៉ូតូទៅឌុបជនរងគ្រោះពីហាងណាណា ទៅផ្ទះជួលរបស់ជនរងគ្រោះ ។ ពេលទៅដល់ផ្ទះជួលបានជួបបុរស [redacted] បុប្ផ ដែលបានចេញមកចាក់សោររបង ដើម្បីចេញយកឯកសារទៅផ្ញើគេខាងក្រៅ ។ ក្រោយពីយកម៉ូតូរបស់ជនរងគ្រោះបណ្តើរចូលក្នុងបន្ទប់ជួលរួចហើយ ខ្លួនក៏ធ្វើដំណើរចេញទៅភ្នំពេញ ដោយទៅដល់ភ្នំពេញនៅម៉ោងប្រហែល១២យប់ ។

-តាមចម្លើយជនជាប់ចោទឆ្លើយថា នៅពេលទៅដល់ផ្ទះឪពុកម្តាយខ្លួន ខ្លួនបានទូរស័ព្ទហៅម្តាយឱ្យបើកទ្វារ នៅម៉ោងប្រហែល១២យប់ ។ ចម្លើយនេះគឺជាចម្លើយភូតកុហក ដោយផ្អែកតាមកំណត់ត្រារបាយការណ៍តាមដានការប្រើប្រាស់លេខទូរស័ព្ទចាប់ពីថ្ងៃទី០១-០២-២០១៤រហូតដល់ថ្ងៃទី១០-០២-២០១៤ គឺនៅថ្ងៃទី០៩-០២

-២០១៤ ឈ្មោះ [redacted] ម៉ារ៉ែន ពុំបានទូរស័ព្ទទៅម្តាយរបស់ខ្លួននៅម៉ោងប្រហែល១២យប់នោះទេ ។ ប៉ុន្តែឈ្មោះ [redacted] ម៉ារ៉ែន បានប្រើទូរស័ព្ទរបស់ខ្លួនលេខ០១២ ៤១ ៧៨ ៧០ តេទៅកាន់លេខទូរស័ព្ទម្តាយរបស់ខ្លួន០១២ ៣៦ ៥៩ ៥៦ នៅវេលាម៉ោង៥និង៣០នាទីទៀបភ្លឺនៅថ្ងៃទី១០-០២-២០១៤ ។

-នៅថ្ងៃទី០៩-០២-២០១៤ ខណៈដែលជនរងគ្រោះឈ្មោះ [redacted] សាថាត អង្គុយហូបស្រាបៀរនៅហាងណាណា ឈ្មោះ [redacted] ម៉ារ៉ែន បានព្យាយាមទូរស័ព្ទទៅកាន់លេខទូរស័ព្ទរបស់ជនរងគ្រោះ០៩៩ ៩៧ ៦៤ ០៦ ចំនួន០៧ដង ចន្លោះពីម៉ោង១៩និង៣២នាទីទៅម៉ោង២០និង៥៨នាទី ។ ឯជនរងគ្រោះហៅទូរស័ព្ទទៅជនជាប់ចោទវិញចំនួន០២ដង ត្រង់នេះបញ្ជាក់ថាជនជាប់ចោទ មិនមានឱកាសច្រៀងខារ៉ាអូខេដូចបានឆ្លើយនោះឡើយ ជនជាប់ចោទបានព្យាយាមទំនាក់ទំនងមកជនរងគ្រោះ ដើម្បីចង់ដឹងថា ជនរងគ្រោះស្រវឹងស្រាហើយឬនៅ និងដើម្បីឱ្យជនរងគ្រោះជឿទុកចិត្តមកលើខ្លួន ។ ម្យ៉ាងទៀតជនជាប់ចោទបានព្យាយាមលាក់នូវគំរោងការប្រព្រឹត្តបទល្មើសរបស់ខ្លួន ដោយប្រាប់មិត្តភ័ក្រ្តខ្លួនថាខ្លួននៅចាំគេមកយកទៅផ្ទះ ប៉ុន្តែតាមការពិតជនជាប់ចោទបានប្រើប្រាស់ម៉ូតូរបស់ជនរងគ្រោះ ជិះចេញពីខារ៉ាអូខេ ទៅឌុបជនរងគ្រោះនៅឯហាង"ណាណា"ទៅផ្ទះជួលរបស់ជនរងគ្រោះ ។

-ជនជាប់ចោទបានព្យាយាមចេញពីផ្ទះរបស់ឪពុកម្តាយខ្លួននៅភ្នំពេញទៅស្នាក់នៅខេត្តក្រចេះដោយលើកហេតុផលថា ខ្លួនទៅព្យាបាលជំងឺនៅទីនោះ និងទៅមើលចំការរបស់ឪពុក ។ ចំណុចនេះគឺជាការភូតកុហក ព្រោះថារយះពេល០៥ថ្ងៃ ជនជាប់ចោទមានមុខងារជានគរបាលមិនបានសុំច្បាប់អង្គភាពឈប់សំរាកព្យាបាលជំងឺឡើយ ។ ហើយម្យ៉ាងទៀតក្នុងរយះពេល០៥ថ្ងៃនេះដែរ ជនជាប់ចោទមិនបានទាក់ទងមកជនរងគ្រោះ តាមទូរស័ព្ទម្តងណាឡើយ ។ ត្រង់នេះបញ្ជាក់ថា ជនជាប់ចោទបានគេចខ្លួនពីការតាមចាប់របស់មន្រ្តីនគរបាលយុត្តិធម៌ ។

-តាមចម្លើយសាក្សីដែលជាអ្នកបំរើស្រាបៀរនៅហាងណាណា បានបញ្ជាក់ថា នៅយប់កើតហេតុនោះជនរងគ្រោះមកផឹកស្រាបានបង្ហាញខ្សែកមាសដល់អ្នកបំរើថា ខ្សែកនេះមានទម្ងន់ជិត២តម្លឹងមាស ។ ឯកូនរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថាឪពុករបស់ខ្លួនមានខ្សែកមាស ហើយមានប្រាក់៣.០០០ដុល្លារនៅនឹងខ្លួនគាត់ ។

-តាមការចង្អុលបង្ហាញខាងលើ បញ្ជាក់ថាជនជាប់ចោទជាអ្នករៀបគំរោងសំលាប់ជនរងគ្រោះ ដើម្បីយកទ្រព្យសម្បត្តិដែលមានខ្សែកនិងប្រាក់ដុល្លារ ហើយបានដុតសំលាប់ជនរងគ្រោះនៅវេលាម៉ោងប្រហែល២៣,៣០នាទីយប់ នៅពេលជនរងគ្រោះស្រវឹងដេកជាំ ហើយក៏ចាកចេញទៅភ្នំពេញក្រោយពីដុតហើយ ។ ជនជាប់ចោទបានទៅដល់ភ្នំពេញនៅម៉ោង០៥និង៣០នាទី ទៀបភ្លឺថ្ងៃទី១០-០២-២០១៤ ពុំមែនទៅដល់ភ្នំពេញនៅម៉ោង១២យប់ឡើយ ។

-មានតែមធ្យោបាយដុតជនរងគ្រោះតែមួយគត់ ដែលជនជាប់ចោទធ្វើដើម្បីបំផ្លាញនៅភស្តុតាងនានាក្នុងគោលបំណងបំភាន់ភ្នែកមហាជន និងសមត្ថកិច្ច ។

-តាមសកម្មភាពរបស់ឈ្មោះ [redacted] **ម៉ារ៉ែន** និងចំលើយសាក្សីបំភ្លឺបានឆ្លើយស៊ីសង្វាក់គ្នា បញ្ជាក់ថាឈ្មោះហេង ម៉ារ៉ែនពិតជាបានប្លន់យកខ្សែករបស់ជនរងគ្រោះ ហើយចាក់សាំងដុតជនរងគ្រោះឱ្យស្លាប់ប្រាកដមែន ។ នេះជាអំពើ **ឃាតកម្មគិតទុកជាមុន** តាមមាត្រា២០០នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ែន** ជាមន្ត្រីនគរបាល ហើយបំរើការនៅស្នងការនគរបាលខេត្តកំពង់ចាមធ្លាប់មានគុណបំណាច់បំរើការងារជូនអង្គភាពក្នុងរយៈពេលកន្លងមក តុលាការគប្បីផ្តល់ស្ថានសម្រាលតាមមាត្រា៩៣,៩៥ នៃក្រមព្រហ្មទណ្ឌ ។

-វត្ថុតាងរួមមានៈ ទូរស័ព្ទដៃ អិនចុចពិល ចំនួន០២គ្រឿង(ពណ៌ក្រហម និងពណ៌ខ្មៅ) ប្រាក់ដុល្លារ ចំនួន៣៥០$(បីរយហាសិប)ដុល្លារអាមេរិក គប្បីតុលាការធ្វើការរឹបអូសតាមមាត្រា៦២ និង៦៣នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វល័ក្ខណ៏ ភេទស្រី អាយុ២៥ឆ្នាំ ជាកូនបង្កើតជនរងគ្រោះ បានប្តឹងទាម

ទារសំណងជួសជុលនូវភាពអន្តរាយ និងជម្ងឺចិត្តចំនួន ១០០.០០០$ ( មួយរយពាន់) ដុល្លារអាមេរិក គប្បីតុលាការពិចារណាតាមច្បាប់ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]គីមស្រ៊ី ជាម្ចាស់ផ្ទះមិនប្តឹងទាមទារសំណងការខូចខាតនិងជម្ងឺចិត្តទេ គប្បីតុលាការមិនលើកយករឿងនេះមកពិចារណាឡើយ ។

## ហេតុដូច្នេះតុលាការ
## វិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសឈ្មោះ[redacted] **ម៉ារីន** ភេទប្រុស អាយុ៤៤ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៣០ **"សាមសិប"** ឆ្នាំ ពីបទៈ **ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៤ តាមមាត្រា២០០ និងមាត្រា៩៣,៩៥ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ[redacted] **ម៉ារីន** សងសំណងការអន្តរាយ និងជម្ងឺចិត្តជាទឹកប្រាក់ ចំនួន ៤០. ០០០.០០០ "សែសិបលាន"រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] **វល័ក្ខណ៍** ការទាមទារលើសនេះ លើកចោល ។

៣-វត្ថុតាងរួមមានៈ ទូរស័ព្ទដៃ អិនចុចពិល ចំនួន០២គ្រឿង( ពណ៌ក្រហម និងពណ៌ខ្មៅ) ប្រាក់ដុល្លារ ចំនួន៣៥០$( បីរយហាសិប) ដុល្លារអាមេរិក ត្រូវរឹបអូសតាមមាត្រា៦២ និង៦៣ នៃក្រមព្រហ្មទណ្ឌ ។

៤-សាលក្រមនេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៨-១០-២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២១-១១-២០១៤ ចំពោះមុខជនជាប់ចោទឈ្មោ[redacted]**ម៉ារីន** និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]**វល័ក្ខណ៍** កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]**គីមស្រ៊ី** ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|---|
| ហត្ថលេខានិងត្រា[redacted] | ហត្ថលេខា[redacted] | ហត្ថលេខា[redacted] | ហត្ថលេខានិង[redacted] |

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
កំពង់ចាម ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៤
**ក្រឡាបញ្ជី**

[redacted]

បានឃើញ
ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៤
**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

[redacted]